**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម**
**ក្រុមលទ្ធកម្ម**
លេខ៖ ......០៩/១៩...... អយក.កច.ក្រល

## សេចក្តីជូនដំណឹងស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារ

**១.ជួសជុលរបង និងចាក់បេតុងផ្លូវចូល និងជួសជុលសំណង់អគារសិក្សាវិទ្យាល័យព្រះសីហនុ ក្រុងកំពង់ចាម ១០បន្ទប់ ស្ថិតក្នុងក្រុងកំពង់ចាម ២.ជួសជុលសំណង់អគារការិយាល័យអប់រំ យុវជននិងកីឡាស្រុក និងជួសជុលរបងសាលាបឋមសិក្សា អនុវិទ្យាល័យពង្រស្ថិតក្នុងស្រុកកោះសូទិន និង៣.ជួសជុលអគារសិក្សាសាលាបឋមសិក្សាក្បាលកោះ ៥បន្ទប់ ស្ថិតក្នុងស្រុកស្រីសន្ធរ**

មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុល របងប្រវែង១១៥ម៉ែត្រ និងចាក់បេតុងផ្លូវចូលការិយាល័យអប់រំ យុវជននិងកីឡាក្រុងកំពង់ចាម និងជួសជុលសំណង់អគារសិក្សាវិទ្យាល័យព្រះសីហនុ ១០បន្ទប់ ក្នុងក្រុងកំពង់ចាម ជួសជុលសំណង់អគារការិយាល័យអប់រំ យុវជននិងកីឡាស្រុកកោះសូទិន ជួសជុលរបងសាលាបឋមសិក្សា អនុវិទ្យាល័យពង្រ ប្រវែង១៤០ម៉ែត្រ ក្នុងស្រុកកោះសូទិន និងជួសជុលអគារសិក្សាសាលាបឋមសិក្សាក្បាលកោះ ៥បន្ទប់ ក្នុងស្រុកស្រីសន្ធរ។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃ មានដាក់លក់នៅការិយាល័យក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ដែលមានអាសយដ្ឋាន ភូមិទី១៥ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ចាប់ពីថ្ងៃទី...២០......ខែ..មិថុនា....ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៤២ ៩៤១ ៣០០)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី..២០........ខែ.កក្កដា.....ឆ្នាំ២០១៨ វេលាម៉ោង...១០.ម៉.៣០...........។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡាខេត្ត តាមអាសយដ្ឋានខាងលើ វេលាម៉ោង....១០.ម៉.៣០..............ថ្ងៃទី..២០.......ខែ.កក្កដា.....ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅកំពង់ចាម, ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨
**ប្រធានមន្ទីរ និងជាប្រធានក្រុមលទ្ធកម្ម**

**លី ម៉េងសាន**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- ក្រសួងអប់រំ យុវជន និងកីឡា (អង្គភាពលទ្ធកម្ម)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ